ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

- លេខ : ២៦៣/០០១/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧
- លេខ : ២៦៤/០០២/២០១៧
  ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៧

**សេចក្ដីសម្រេច**

លេខ : ១៦១/០០១/២០១៧ កបធ.ច

ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្ដីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០១/០១៧ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេច សង្កាត់លេខ១ ក្រុងព្រះសីហនុ តែបដិសេធ ០២នាក់ ក្នុងចំណោម ៤១នាក់ ដែលមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលតម្កល់សេចក្ដីសម្រេចលេខ ០១ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៧

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

របស់ក្រុមប្រឹក្សាប្រជុំសម្រេច សង្កាត់លេខ២ ក្រុងព្រះសីហនុ តែបដិសេធ ១២នាក់ ក្នុងចំណោម ៣៥នាក់ ដែលមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោក **សឿន ឆី** ជូនលោកមេធាវី **ផែន ហេង** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេច លេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោក **តុំ អ៊ួន** ជូនលោកមេធាវី **ផែន ហេង** ដើម្បីធ្វើជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេច លេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតលេខ ០៧៨ គ.ជ.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **មាន សតិ** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោកមេធាវី **ផែន ហេង**
- បានឃើញលិខិតលេខ ០៨៩ គ.ជ.ប ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម **ទេព នីថា** និងឯកឧត្តម **សំ សាវុធ** ដើម្បីមកបំភ្លឺលើពាក្យបណ្តឹងរបស់លោកមេធាវី **ផែន ហេង**
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៧ របស់លោកមេធាវី **ផែន ហេង** តំណាងដោយអាណត្តិឲ្យលោក **សឿន ឆី** និង លោក **តុំ អ៊ួន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៦ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ និង លេខ ០០៧ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៧ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី **ផែន ហេង** កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម **មាន សតិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ ដោយភ្ជាប់សារណាចំនួន ០២ ច្បាប់ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ៧៦នាក់ ដែលត្រូវបានប្តឹងថាជាជនជាតិបរទេស (វៀតណាម)
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតនៅសង្កាត់លេខ១ និងសង្កាត់លេខ២ នៅក្រុងព្រះសីហនុ របស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៧

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់លោកមេធាវី ផែន ហេង**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**